# សង្ខេបរបាយការណ៍រួមស្តីពីការរៀបចំការបោះឆ្នោត នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០១៣

## សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត




ខែវិច្ឆិកា ឆ្នាំ២០១៣
ភ្នំពេញ ប្រទេសកម្ពុជា

# របាយការណ៍ស្តីពីការបោះឆ្នោតនៅកម្ពុជាឆ្នាំ២០១៣

## *I. សេចក្តីផ្តើម*

១. កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ កម្ពុជាបានធ្វើការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៥ ដែលគិតចាប់ពីកាបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក(UNTAC) ក្នុងឆ្នាំ១៩៩៣រហូតមក។ ជាទូទៅការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជារួមទាំងការបោះឆ្នោតក្នុងខែកក្កដាកន្លងទៅ មិនត្រូវបានប្រព្រឹត្តតាមស្តង់ដារអន្តរជាតិនោះទេ ហើយតែងតែមានការរិះគន់ពីអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ជាពិសេសទៅលើការគ្រប់គ្រងរដ្ឋបាលបោះឆ្នោត។

២. ដំណើរការប្រព្រឹត្តទៅប្រកបដោយភាពវិជ្ជមាន ប៉ុន្តែនៅមានកំរិត បើទោះបីជាមានការសុំលើកលែងទោសឯកឧត្តសម រង្ស៊ី ដែលជាប្រធានគណបក្សប្រឆាំង ពីសំណាក់នាយករដ្ឋមន្ត្រី ហ៊ុនសែន ដែលត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រកម្ពុជា ព្រះបាទនរោត្តម សីហមុនី ។ ខណៈពេលដែលការលើកលែងទោសត្រូវបានគេធ្វើឡើងគាកនឹងថ្ងៃបោះឆ្នោត ហើយមិនបានទុកឪកាសអោយមេដឹកនាំប្រឆាំងរូបនេះអាចឈរឈ្មោះជាបេក្ខជន រឺបោះឆ្នោតបាននោះទេ តែបានត្រឹមអោយឯកឧត្តម សម រង្ស៊ីត្រឡប់មកប្រទេសរបស់ខ្លួនវិញសម្រាប់ពេលបោះឆ្នោត និងចូលរួមការធ្វើយុទ្ធការឃោសនាបោះឆ្នោតតែប៉ុណ្ណោះ។ បញ្ហាទាំងនេះអាចជះឥទ្ធិពល បើទោះបីជាពិបាកក្នុងការវាស់វែង ប៉ុន្តែជះឥទ្ធិពលដល់បរិយាកាសនយោបាយ។

៣. អ្វីដែលគួរឲ្យកត់សំគាល់គឺការថយចុះអំពើហឹង្សាក្នុងដំណើរការបោះឆ្នោត។ ជាងនេះទៅទៀត គឺមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលអាចឲ្យប្រជាពលរដ្ឋទទួលបាននូវព័ត៌មាននយោបាយដែលខុសពីការបោះឆ្នោតអាណត្តិមុន។

៤. មានបញ្ហាប្រឈមជាច្រើនដែលធ្វើឲ្យដំណើរការបោះឆ្នោតមិនសូវមានទំនុកចិត្ត។ ជាពិសេស មុន និងថ្ងៃបោះឆ្នោត អ្នកសង្កេតការណ៍បានរាយការណ៍ពីភាពមិនប្រក្រតី ដែលក្នុងនោះរួមមាន ការបដិសេធប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតពីបញ្ជីបោះឆ្នោត ការបញ្ចូលអ្នកគ្មានសិទ្ធិបោះឆ្នោត ឬមានឈ្មោះស្ទួនក្នុងបញ្ជីបោះឆ្នោត ការចែកចាយឯកសារដូចជាលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់ឲ្យការបោះឆ្នោតជាច្រើន និងការមិនកែប្រែចំនួនអាសនៈសម្រាប់មណ្ឌលបោះឆ្នោតនីមួយៗទៅតាមច្បាប់ដែលបានកំនត់។

៥. ជាលទ្ធផលនៃបញ្ហាដែលបានកើតឡើង បានជៈឥទ្ធិពលេនៅថ្ងៃបោះឆ្នោត ដែលធ្វើឲ្យអ្នកមានសិទ្ធិបោះឆ្នោតជាច្រើនមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ផ្ទុយទៅវិញអ្នកមិនមានសិទ្ធិបោះឆ្នោតបែរជាត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតដោយគ្មានឯកសារជាក់លាក់ ដែលនាំអោយប៉ះពាល់ដល់សុច្ចរិតភាពនៃដំណើរការបោះឆ្នោត។ បញ្ហាទាំងនេះកើតឡើងក្នុងទំហំមិនស្មើគ្នាទៅតាមមណ្ឌលបោះឆ្នោតនីមួយ ដែលនាំឲ្យគុណភាពនៃការបោះឆ្នោតនៅមានកំរិត ព្រមទាំងអាចជៈឥទ្ធិពលដល់សម្លេងឆ្នោតរបស់គណបក្សនយោបាយទាំងពីរដែលសម្លេងឆ្នោតទទួលបានខុសគ្នាតិចជាង៣០០,០០០សន្លឹកក្នុងចំណោម៦,៦លាន។

៦. ភាពមិនប្រក្រតីធ្ងន់ធ្ងរជាច្រើនបានធ្វើឲ្យមានការមិនទុកចិត្តទៅលើដំណើរការបោះឆ្នោតទាំងមូល ជាពិសេសលទ្ធផលបោះឆ្នោត ដែលជាហេតុនាំឲ្យមេដឹកនាំគណបក្សសង្គ្រោះជាតិបដិសេដមិនទទួលយកលទ្ធ

ផលនៃការបោះឆ្នោត ហើយអ្នកគាំទ្ររបស់គណបក្សនេះនាំគ្នាធ្វើបាតុកម្ម ដើម្បីទាមទារឲ្យមានកំណែទំរង់ការបោះឆ្នោត។

៧. កំណែទម្រង់ការបោះឆ្នោតត្រូវតែជាអាទិភាពទី១ ហើយត្រូវតែបង្កើតឲ្យមានស្ថាប័នឯករាជ្យពិតប្រាកដមិនលំអៀង មិនចូលរួមក្នុងគណបក្សនយោបាយ មានតម្លាភាព គណនេយ្យភាព ដែលទទួលខុសត្រូវក្នុងដំណើរការបោះឆ្នោតទាំងមូល ដើម្បីឲ្យមានភាពជឿជាក់ពីម្ចាស់ឆ្នោត និងគ្រប់គណបក្សនយោបាយទាំងអស់ ព្រមទាំងអង្គការសង្គមស៊ីវិល។ ជាងនេះទៅទៀត ត្រូវតែមានកំណែទម្រង់ទៅលើការចុះឈ្មោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ....។ល។

៨. របាយការណ៍របស់សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត មានគោលបំណងបង្ហាញពីភាពមិនប្រក្រតីដែលបានយកចេញពីរបាយការណ៍ និងការស្រាវជ្រាវជាច្រើនក្នុងការបោះឆ្នោតនាពេលកន្លងទៅថ្មីៗនេះ។ គោលបំណងនៃរបាយការណ៍នេះ គឺបង្កើតជាគ្រឹះសម្រាប់ការធ្វើកំណែទម្រង់នាពេលអនាគត និងដើម្បីបង្កើននូវភាពជឿជាក់ពីសាធារណៈជន។ នៅក្នុងពេលជាមួយគ្នានេះដែរ ចំនុចមួយចំនួននៅក្នុងរបាយការណ៍នេះក៏បានលើកឡើងអំពីអនុសាសន៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា សហគមន៍អឺរ៉ុប និងអនុសាសន៍របស់អង្គការជាតិ និងអន្តរជាតិដទៃទៀតផងដែរ។

## II. វិធីសាស្ត្រ

៩. របាយការណ៍នេះត្រូវបាចងក្រងឡើងដោយផ្អែកលើការស្រាវជ្រាវរបស់អង្គការដែលមានភាពឯករាជ្យជាច្រើនដូចជា គណៈកម្មាធិការអព្យាក្រឹត និងមិនលំអៀងសម្រាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅក្នុងកម្ពុជា(NICFEC), វិទ្យាស្ថានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ (NDI), មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជាន់ខ្ពស់ (CAS) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL), អង្គការលីកាដូ (LICADHO) និងអង្គការតម្លាភាពអន្តរជាតិនៃកម្ពុជា (TIC)។ ទោះបីជាការសិក្សាទាំងនេះផ្តល់ព័ត៌មានលំអិតនៃការបោះឆ្នោតយ៉ាងណាក៏ដោយ ប៉ុន្តែការធ្វើការសន្និដ្ឋាននៅក្នុងរបាយការណ៍នេះនៅមានកំរិត ដោយសារតែ គ.ជ.ប មិនបានរួមសហការក្នុងការផ្តល់ទិន្នន័យ ឧទាហរណ៍៖ មិនមានទិន្នន័យជាផ្លូវការណាមួយនៃចំនួនលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឲ្យការបោះឆ្នោត និងមិនផ្តល់ឯកសារជាតួលេខនៃសន្លឹកឆ្នោតមិនបានការនៅតាមការិយាល័យបោះឆ្នោតនីមួយៗ។ គ.ជ.បមិនបានផ្តល់ទិន្នន័យនៃបញ្ជីឈ្មោះអ្នកបោះឆ្នោតទាំងអស់ឲ្យត្រូវតាមទំរង់ត្រឹមត្រូវសម្រាប់ជាការវិភាគ និងការពិនិត្យផ្ទៀងផ្ទាត់នោះទេ។

## *III. សាវតា*

### ក.រដ្ឋបាលបោះឆ្នោត

១០. គ.ជ.ប មានតួនាទីធ្វើឲ្យដំណើរការបោះឆ្នោតមានភាពត្រឹមត្រូវ និងជឿជាក់ពីម្ចាស់ឆ្នោត ព្រមទាំងគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែង។ គ.ជ.បក៏មានតួនាទីធ្វើបញ្ជីបោះឆ្នោតផងដែរ។ ប៉ុន្តែកន្លងមកនេះ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិព្រួយបារម្ភអំពីសុចរិតភាព និងអព្យាក្រិត្យភាពនៃស្ថាប័នមួយនេះ ពីព្រោះថាគ.ជ.ប គឺជាស្ថាប័នដែលស្ថិតនៅក្រោមក្រសួងមហាផ្ទៃ។

១១. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា ប្រធាន អនុប្រធាន និងសមាជិក៧រូប ផ្សេងទៀត គួរតែត្រូវជ្រើសរើសក្នុងចំណោមអ្នកមានបទពិសោធន៍ខាងនយោបាយ និងមានកេរ្តិ៍ឈ្មោះល្អ។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ការជ្រើសរើសសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានគេធ្វើឡើង និងឯកភាពពីគណបក្សកាន់អំណាច ដោយគ្មានយន្តការត្រួតពិនិត្យជាសាធារណៈ ឬប្រឹក្សាយោបល់ជាមួយគណបក្សនយោបាយផ្សេងៗ និងអ្នកពាក់ព័ន្ធដ៏ទៃទៀត។ បេក្ខភាពសមាជិករបស់គ.ជ.បត្រូវបានជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអនុម័តដោយគណៈរដ្ឋមន្ត្រីដឹកនាំដោយនាយករដ្ឋមន្ត្រីហ៊ុនសែន ដែលផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភាដឹកនាំដោយគណបក្សកាន់អំណាច។ គ្មានព័ត៌មានណាមួយបង្ហាញពីលក្ខខណ្ឌនៃការជ្រើសរើសសមាជិកគ.ជ.ប ហើយសមាជិកនៃគណកម្មការខេត្តរាជធានីរៀបចំការបោះឆ្នោត គណកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត និងមន្ត្រីការិយាល័យបោះឆ្នោត មិនត្រូវបានតែងតាំងដោយបើកចំហរ ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៣ ប្រធានគណៈកម្មាការរៀបចំការបោះឆ្នោតខេត្តរាជធានី (PEC) ត្រូវបានតែងតាំងសារជាថ្មីព្រមទាំងចាប់ផ្តើមបណ្តុះបណ្តាលមន្ត្រីថ្នាក់ក្រោមរបស់ខ្លួនរួចជាស្រេចមុនពេលចាប់ផ្តើមប្រកាសជ្រើសរើស។

១២. គ.ជ.ប ត្រូវទទួលខុសត្រូវលើបញ្ជីបោះឆ្នោត តែច្បាប់បានប្រគល់ប្រតិបត្តិការដំណើរការចុះឈ្មោះបោះឆ្នោតទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់។ ក្នុងនោះមាន៩៧%នៃឃុំសង្កាត់ ឬមេឃុំសង្កាត់ត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច ដែលបញ្ហានេះអាចផ្តល់ឱកាសឲ្យមន្ត្រីទាំងនេះធ្វើការលំអៀងក្នុងការរៀបចំបញ្ជីបោះឆ្នោត។ ម៉្យាងវិញទៀត មន្ត្រីដែលទទួលខុសត្រូវការអនុវត្តការចុះឈ្មោះបោះឆ្នោតខ្វះការបណ្តុះបណ្តាល ថវិកា និងមានការយល់ដឹងតិចតួចអំពីដំណើរការ និងនិតិវិធី។

១៣. ការមិនមានតម្លាភាពក្នុងអនុវត្តការងាររបស់គ.ជ.ប ទាក់ទងទៅនឹងឯកសារ និងព័ត៌មានមួយចំនួន ឧទាហរណ៍ដូចជា គ.ជ.ប មិនបានធ្វើការផ្សព្វផ្សាយឯកសារសំខាន់ៗ បញ្ជីបោះឆ្នោតត្រូវបានដកចេញពីគេហទំព័ររបស់គ.ជ.បមួយថ្ងៃមុនថ្ងៃបោះឆ្នោត។ សំខាន់ជាងនេះទៅទៀត គ.ជ.បមិនបានផ្តល់ប្រព័ន្ធទិន្នន័យនៃបញ្ជីបោះឆ្នោតទាំងមូលនៅក្នុងទម្រង់ដែលអាចវិភាគបាន (Full voter list database) សម្រាប់ឲ្យគណបក្សនយោបាយ និងអង្គការសង្កេតការណ៍បោះឆ្នោត។

១៤. ការដោះស្រាយបណ្តឹងដោយស្ថាប័នគ.ជ.បគឺមិនស្របតាមបទដ្ឋានអន្តរជាតិ។ មាត្រានៃច្បាប់ និងបទបញ្ជានីតិវិធីបោះឆ្នោតដែលមានស្រាប់មានភាពផ្ទុយគ្នា និងការអនុវត្តនៅមានការខ្វះចន្លោះ។ មន្ត្រីបោះឆ្នោតមូលដ្ឋានត្រូវបានគេចោទប្រកាន់ថាមិនសូវយល់ដឹងច្បាប់ និងសមត្ថភាពក្នុងការដោះស្រាយបណ្តឹងនៅមានកម្រិត។ ពេលកំណត់នៃការដាក់ពាក្យ និងដោះស្រាយបណ្តឹងមានរយៈពេលខ្លី ដោយមិនបានផ្តល់ឱកាសច្រើនដល់អ្នកដាក់ពាក្យបណ្តឹងប្រមូលឯកសារសំខាន់ៗ។

**អនុសាសន៍**

អង្គការដែលធ្វើការទាក់ទងនឹងការបោះឆ្នោតក៏ដូចជាសហគមន៍អ៊ឺរ៉ុប និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ និងអ្នកជំនាញជាច្រើន បានផ្តល់អនុសាសន៍ជាងមួយទសវត្សរ៍កន្លងមកនេះទាក់ទងការកំណែទម្រង់ស្ថាប័នគ.ជ.ប ប៉ុន្តែគ្មានសកម្មភាពណាមួយត្រូវបានគេអនុវត្តតាមអនុសាសន៍ទាំងនេះ។

## ខ. ការចុះឈ្មោះអ្នកបោះឆ្នោត

១៥. ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានបង្កភាពលំបាកជាច្រើនដល់ប្រជាពលរដ្ឋដែលធ្វើចំណាកស្រុក និងកម្មករដែលធ្វើការរយៈពេលខ្លីនៅកន្លែងផ្សេង ពីព្រោះការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតគឺត្រូវធ្វើឡើងក្នុងឃុំសង្កាត់ដែលអ្នកបោះឆ្នោតបានចុះឈ្មោះបោះឆ្នោត។ អ្នកបោះឆ្នោតមួយចំនួនអាចប្រឈមនឹងការបាត់បង់សិទ្ធិបោះឆ្នោត ដោយសារតែពួកគេមិនមានពេលវេលា ឬថវិកាត្រឡប់ទៅទីកន្លែងដើមវិញដើម្បីពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។ ជាពិសេសនៅឆ្នាំដែលមានការបោះឆ្នោត ម្ចាស់ឆ្នោតដែលរស់នៅ ឬធ្វើការងារនៅទីកន្លែងផ្សេងត្រូវតែត្រឡប់មកកន្លែងដែលពួកគេចុះឈ្មោះដើម្បីបោះឆ្នោត ។

១៦. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រើក្នុងការចុះឈ្មោះបោះឆ្នោតនៅតែមានភាពស្មុគស្មាញសម្រាប់ប្រជាពលរដ្ឋ ពីព្រោះរដ្ឋាភិបាលនៅតែពុំទាន់ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋគ្រប់រូប និងឲ្យបានត្រឹមត្រូវ បើទោះបីជាមានគាំទ្រពីអន្តរជាតិទាំងផ្នែកថវិកា និងបច្ចេកទេសក៏ដោយ ។ ប្រជាពលរដ្ឋដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវតែយល់ដឹងអំពីឯកសារផ្សេងៗជាច្រើនសម្រាប់ប្រើការចុះឈ្មោះដើម្បីបំពេញលក្ខខណ្ឌទាំងបួនគឺសញ្ជាតិ អាយុ លំនៅដ្ឋាន និងរូបថត។ ជាងនេះទៅទៀត ការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណដោយមិនត្រឹមត្រូវ អាចនាំឲ្យមានភាពមិនប្រក្រតីកើតឡើងនៅការិយាល័យបោះឆ្នោត និងផ្តល់ឪកាសឲ្យមានការបោះឆ្នោតដោយមិនត្រឹមត្រូវនៅថ្ងៃបោះឆ្នោត។

១៧. ការគ្រប់គ្រងទិន្ន័យ និងប្រមូលទិន្នន័យនៃបញ្ជីបោះឆ្នោតរបស់គ.ជ.បមានភាពស្មុគស្មាញ។ គ.ជ.បប្រើប្រាស់កូដអក្សររបស់ខ្លួនដែលមិនអាចបម្លែងបានជំនួសឲ្យការប្រើប្រាស់អក្សរយូនីកូដដែលជាកូដតែងតែប្រើនៅក្នុងប្រទេសកម្ពុជា។ កំហុសជាច្រើនបានកើតឡើងដោយសារតែការសរសេរដោយដៃ និងប្រព័ន្ធបច្ចេកវិទ្យារបស់គ.ជ.បនៅមានកម្រិត ក្នុងការរៀបចំទិន្នន័យឲ្យមានប្រសិទ្ធភាព។ ក្រុមប្រឹក្សាឃុំសង្កាត់ ជារឿយៗត្អូញត្អែថាបញ្ជីបោះឆ្នោតដែលពួកគេបានបញ្ជូនទៅគ.ជ.ប ហើយបញ្ជីបោះឆ្នោតដែលគ.ជ.បបញ្ជូនត្រឡប់មកវិញនៅតែមានកំហុសក្នុងអំឡុងពេលបញ្ចូលទិន្នន័យ។

**អនុសាសន៍**

អ្នកអង្កេតការណ៍ទទួលស្គាល់ថាត្រូវតែមានការផ្លាស់ប្តូរយ៉ាងសំខាន់នៃការចុះឈ្មោះអ្នកបោះឆ្នោត និងដំណើរការរៀបចំបញ្ជីបោះឆ្នោតក្នុងប្រទេសកម្ពុជាដើម្បីធានាសិទ្ធិបោះឆ្នោតសម្រាប់អ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់ ដើម្បីការពារឈ្មោះមិនត្រឹមត្រូវក្នុងពេលចុះឈ្មោះ ដែលអាចកាត់តបន្ថយលទ្ធភាពក្នុងការលួចបន្លំកាន់តែតិចទៅៗ។

## គ.ប្រព័ន្ធផ្សព្វផ្សាយ

១៨. ការផ្សព្វផ្សាយជាពិសេសវិទ្យុភាគច្រើន និងទូរទស្សន៍ស្ទើរតែទាំងអស់មិនបានឆ្លើយតបទៅនឹងគោលការណ៍របស់គ.ជ.ប ក្នុងការធ្វើឲ្យមានតុល្យភាពនៃព័ត៌មានបោះឆ្នោត និងគោលការណ៍ត្រឹមត្រូវ មិនលំអៀង ព្រមទាំងសមភាពសម្រាប់គណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែងនោះទេ។ នៅក្នុងការឃោសនាបោះឆ្នោតឆ្នាំ២០១៣ ខុមហ្វ្រែលបានធ្វើការអង្កេតទូរទស្សន៍ចំនួនបី ហើយក្នុងនោះរកឃើញថា គណ

បក្សប្រជាជនកម្ពុជាត្រូវបានចាក់ផ្សាយ និងគ្របដណ្តប់៨៧,៩៨%នៃការផ្សាយផ្សាយព័ត៌មាននយោបាយនៅក្នុងទូរទស្សន៍បាយ័នព័ត៌មាន ដែលមានកូនស្រីនាយករដ្ឋមន្ត្រីហ៊ុន សែនជាម្ចាស់ស្ថានីយ ចំនែកឯទូរទស្សន៍ស៊ីធីអិន បានចាក់ផ្សាយប្រមាណ៧៥%នៃការផ្សព្វផ្សាយនយោបាយ។ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ទាំងបីនេះដែរ ក៏ពុំឃើញមានទូរទស្សន៍ណាមួយចាក់ផ្សាយពីការវិលត្រឡប់មកវិញរបស់លោកសម រង្ស៊ី ប្រធានគណបក្សប្រឆាំង ដែលជារឿងធំបំផុតសម្រាប់ឆ្នាំបោះឆ្នោតនេះ។ ខណៈពេលដែលគណបក្សប្រឆាំងមានឱកាសផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម។

១៩. ប្រព័ន្ធផ្សព្វផ្សាយសង្គម និងសេវាអ៊ីនធើណែតបានដើរតួនាទីយ៉ាងសំខាន់សម្រាប់ដំណើរការបោះឆ្នោតនៅប្រទេសកម្ពុជា។ នេះបាននាំឲ្យមានការផ្លាស់ប្តូរយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយធំៗដែលចូលរួមប្រកួតប្រជែង និងបានទៅដល់អ្នកគាំទ្រ និងការចែករំលែកព័ត៌មានតាមរយៈគេហទំព័រ វីដេអូ ហ្វេសបុក និងធ្វីតធើ.....។ល។ ប្រព័ន្ធផ្សព្វផ្សាយសង្គមនេះបានផ្តល់អត្ថប្រយោជន៍ដល់គណបក្សប្រឆាំងខណៈពេលដែលពួកគេទទួលបានការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ និងវិទ្យុតិចតួច។ មិនតែប៉ុណ្ណោះ អង្គការសង្គមស៊ីវិលក៏បានបង្កើនការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមនេះផងដែរ។

**អនុសាសន៍**

អង្គការជាច្រើនបាននឹងកំពុងធ្វើការតស៊ូមតិទាក់ទងទៅនឹងកំណែទម្រង់ជាមូលដ្ឋានដើម្បីធានាអោយមានវិជ្ជាជីវៈ គុណភាព និងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយចំរុះកាន់តែប្រសើរឡើង។

## ឃ.ការប្រើប្រាស់ធនធានរដ្ឋមិនត្រឹមត្រូវ

២០. ការប្រើប្រាស់ធនធានរដ្ឋដោយគណបក្សកាន់អំណាចមានចាប់តាំងពីការបោះឆ្នោត១៩៩៣មកម្ល៉េះ។ គណបក្សប្រជាជនកម្ពុជាបានបង្កើតរចនាសម្ព័ន្ធនៅគ្រប់កំរិតក្នុងជួរមន្ត្រីរាជការ ប៉ូលីស ទាហាន និងកងកម្លាំងប្រដាប់អាវុធ ដែលផ្ទុយពីច្បាប់។ យោងទៅលើការអង្កេតនៅក្នុងការបោះឆ្នោតឆ្នាំ២០០៣ និង២០០៨បានឲ្យដឹងថាវត្តមានរបស់ប៉ូលីស ទាហាន និងមន្ត្រីរាជការមួយចំនួនមិនត្រឹមតែចូលរួមការឃោសនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កឲ្យមានអំពើហឹង្សាទៀតផង។ គិតចាប់ពីថ្ងៃទី១ ខែកញ្ញាឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៣ ការសង្កេតរបស់ខុមហ្វ្រែលបានរកឃើញមានការប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យគណបក្សប្រជាជនកម្ពុជាមានលក្ខណៈជាប្រព័ន្ធចំនួន៣៨៣ករណីដូចជាមន្ត្រីរាជការ នគរបាល តុលាកា កងខេមរភូមិន្ទ និងការប្រើប្រាស់នូវអគាររដ្ឋនិងទីធ្លាសាធារណ៍ក្នុងការឃោសនាសម្រាប់គណបក្សប្រជាជនកម្ពុជា។ ដូចគ្នាដែរ បើផ្អែកលើរបាយការណ៍ឃ្លាំមើលសិទ្ធិមនុស្ស (Human Right Watch) នៅឆ្នាំ២០១៣ ទាហាន ប៉ូលីស កងរាជអាវុធហត្ថ ត្រូវបានចូលរួមក្នុងសកម្មភាពមិនអព្យាក្រិត្យ ដែលរួមទាំងការថ្លែងការគាំទ្រក្នុងពេលឃោសនា ដែលបានបង្កើតបរិយាកាសបំភិតបំភ័យ ទៅដល់ម្ចាស់ឆ្នោតនៃទូទាំងប្រទេសមុនការបោះឆ្នោត។

**អនុសាសន៍**

អ្នកសង្កេតការណ៍ឯករាជ្យបានផ្តល់អនុសាសន៍ជាបន្តបន្ទាប់ដើម្បីការពារការប្រើប្រាស់ធនធានរដ្ឋគោលបំណងបំរើឲ្យគណបក្សរបស់ខ្លួន។

## ង. ការបែងចែកអាសនៈ

២១. បើទោះបីចំនួនប្រជាពលរដ្ឋមានការកើនឡើងក៏ដោយ ប៉ុន្តែចំនួនអាសនៈនៃរដ្ឋសភាមិនមានការផ្លាស់ប្តូរទេក្នុងរយៈពេលមួយទស្សវត្តចុងក្រោយនេះ។ ព្រះរាជក្រម លេខនស/រកម/១១២/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ ចំនួនអាសនៈនៅក្នុងការជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៥ក្នុងរដ្ឋសភាត្រូវបានគេកំណត់ត្រឹម១២៣អាសនៈ។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់បោះឆ្នោតបានបញ្ជាក់ថានៅពេលដែលមានតំរូវការ ចំនួនអាសនៈអាចនឹងមានការប្រែប្រួល ឬរក្សាទុកដដែលក្នុងខេត្តណាមួយ ដោយផ្អែកលើកំណើនប្រជាពលរដ្ឋ។

២២. ទំហំ និងការបែងចែកនៃការបោះឆ្នោតថ្នាក់ស្រុក ខណ្ឌ អាចជះឥទ្ធិពលយ៉ាងខ្លាំងនៅថ្ងៃបោះឆ្នោត។ តំណាងដែលមានលក្ខណៈសមាមាត្រអាចជាប់ទាក់ទងនឹងចំនួនអាសនៈដែលបែងចែកទៅឲ្យគណបក្សនយោបាយមួយគួរតែសមាមាត្រទៅនឹងចំនួនសន្លឹកឆ្នោតដែលគណបក្សនយោបាយមួយទទួលបាន។ ការទទួលបានអាសនៈរបស់គណបក្សប្រជាជនកម្ពុជាគឺច្រើនជាងសន្លឹកឆ្នោតដែលគណបក្សនេះទទួលបាន ហើយភាគច្រើនគឺនៅមណ្ឌលបោះឆ្នោតដែលមានតែមួយអាសនៈ (៩មណ្ឌលបោះឆ្នោតនៅទូទាំងប្រទេសកម្ពុជាដែលគណបក្សប្រជាជនកម្ពុជាឈ្នះនៅគ្រប់មណ្ឌលនេះទាំងអស់)។

អានុសាសន៍

- ការបែងចែកអាសនៈតាមមណ្ឌលនីមួយៗឡើងវិញ គឺត្រូវបានតម្រូវដោយច្បាប់។ ពីព្រោះថាបើយោងតាមរូបមន្តនៅក្នុងច្បាប់បោះឆ្នោត ដែលគួរតែមាន១៣៨អាសនៈនៅក្នុងរដ្ឋសភា (ប្រសិនបើយោងតាមស្ថិតិប្រជាពលរដ្ឋ) ឬ១៣៧អាសនៈ (ប្រសិនបើយោងតាមចំនួនប្រជាពលរដ្ឋតាមឃុំសង្កាត់)

# IV. ការបោះឆ្នោត២០១៣៖ របកគំហើញសំខាន់ៗ

## ក. ការបដិសេធប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត

២៣. សវនកម្មដំបូងរបស់អង្គការ NICFEC-NDI បានបង្ហាញថា ១០,៨%នៃមនុស្សដែលគិតថាខ្លួន បានចុះឈ្មោះបោះឆ្នោតរួច តែមិនមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ។ នៅក្នុង SVRA Plus របស់អង្គការខុមហ្វ្រែល បានរកឃើញថា ១៣,៥%នៃអ្នកបោះឆ្នោតដែលបាននិយាយថាពួកគេបានទៅចុះឈ្មោះបោះឆ្នោត ប៉ុន្តែទិន្នន័យរបស់ពួកគេមិនបានកត់ត្រានៅលើបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ (ឈ្មោះរបស់ពួកគេមិនអាចរកឃើញ ឬឈ្មោះ/ទិន្នន័យរបស់ពួកគេត្រូវបានផ្លាស់ប្តូរទាំងស្រុង) ។ យោងតាមរបាយការណ៍របស់អង្គការខុមហ្វ្រែល មានប្រជាពលរដ្ឋប្រមាណ ១,២៥ លាននាក់ ដែលមិនមានទិន្នន័យនៅក្នុងបញ្ជីបោះឆ្នោត។

២៤. សវនកម្មរបស់ គ.ជ.ប ដែលបានធ្វើឡើងដោយក្រុមហ៊ុនឯករាជ្យ បានរកឃើញថា ៩% នៃឈ្មោះអ្នកដែលមានសិទ្ធិបោះឆ្នោត ជឿជាក់ថាខ្លួនបានទៅចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ទោះជាយ៉ាងណា នៅពេលដែល គ.ជ.ប បានផ្ទៀងផ្ទាត់ជាមួយនឹងមូលដ្ឋានទិន្នន័យខាងក្នុងរបស់ខ្លួន តួលេខបានធ្លាក់ចុះ ៣% ដោយបាន

បញ្ជាក់ថាឈ្មោះដែលបានរកឃើញបន្ថែម "មិនត្រឹមត្រូវ" នៅក្នុងបញ្ជីបោះឆ្នោត ។ ប្រសិនបើមានករណីដូចនេះ ថាតើ គ.ជ.ប ផ្ទៀងផ្ទាត់ឈ្មោះដែលត្រឹមត្រូវដូចម្តេច ឬ ថាតើមនុស្សម្នាក់អាចបោះឆ្នោតបានដោយរបៀបណា នៅថ្ងៃបោះឆ្នោត ប្រសិនបើទិន្នន័យរបស់ពួកគេមិនដូចទៅនឹងបញ្ជីបោះឆ្នោត? លើសពីនេះ ទោះបីជា គ.ជ.ប បានរកឃើញឈ្មោះមនុស្សទាំងនោះនៅក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែនៅតែមិនមានភាពច្បាស់លាស់ *ថាតើទិន្នន័យ និងឈ្មោះរបស់ពួកគេត្រូវបានរកឃើញនៅកន្លែងណា*។ ឧទាហរណ៍៖ ប្រសិនបើមាននរណាម្នាក់នៅខេត្តកំពង់ចាម គិតថាខ្លួននឹងត្រូវបានបោះឆ្នោតនៅក្នុងខេត្តកំពង់ចាម ផ្ទុយទៅវិញករណីនេះនឹងអាចមានបញ្ហាប្រសិនបើឈ្មោះរបស់គាត់ត្រូវបានរកឃើញនៅក្នុងបញ្ជីបោះឆ្នោតដែលស្ថិតនៅក្នុងខេត្តព្រៃវែង។

២៥. យោងតាមការរកឃើញរបស់ NDI និងTIC ៦០% នៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតមួយចំនួនដែលមានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវ មិនអាចរកឃើញឈ្មោះរបស់ខ្លួននៅក្នុងបញ្ជីបោះឆ្នោត និងមិនអាចបោះឆ្នោតបាននៅក្នុងទីតាំងនោះ។ ចំណែកឯការរកឃើញរបស់ខុមហ្វ្រែល ៤៨,៣០%នៃអ្នកមានសិទ្ធិបោះឆ្នោត បានទៅដល់ការិយាល័យបោះឆ្នោត ប៉ុន្តែមិនអាចបោះឆ្នោតបានដោយសារតែពួកគេមិនមានឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវ រកឈ្មោះមិនឃើញនៅក្នុងបញ្ជីបោះឆ្នោត ឬ បានរកឃើញ តែមិនដូចគ្នារវាងឯកសារអត្តសញ្ញាណ និងព័ត៌មានដែលបានកត់ត្រានៅក្នុងបញ្ជីបោះឆ្នោត។

## ខ. ឈ្មោះមិនបានការ និងការបោះឆ្នោតមិនត្រឹមត្រូវ

២៦. ៨០,៧% នៃឈ្មោះដែលមាននៅក្នុងបញ្ជីបោះឆ្នោត ត្រូវបានផ្ទៀងផ្ទាត់ថាត្រឹមត្រូវ ដោយ ៣,៦%គឺជាប្រជាជនដែលរស់នៅក្នុងកន្លែងដែលពួកគេបានចុះឈ្មោះ និង ១៧,១% ផ្សេងទៀត នៃឈ្មោះដែលមាននៅក្នុងបញ្ជីបោះឆ្នោត គឺជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែរស់នៅកន្លែងផ្សេងទៀតជាបណ្តោះអាសន្ន[4] ។ អ្វីដែលសំខាន់នោះគឺ ក្រុមអ្នកបោះឆ្នោតដែលមានទីលំនៅបណ្តោះអាសន្ន - ជាភាគរយដ៏សំខាន់នៃការចុះឈ្មោះបោះឆ្នោតជារួម - ចាំបាច់ធ្វើដំណើរទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។ ១០,៤% បន្ថែមទៀត នៃឈ្មោះដែលមាននៅក្នុងបញ្ជីបោះឆ្នោត មិនត្រូវបាននរណាម្នាក់ស្គាល់ថាជា សមាជិកសហគមន៍ រួមទាំងមេភូមិ គណកម្មការវត្ត ប៉ូលីស និងអ្នកជិតខាង (យោងតាមVRA របស់ NDI និងNICFEC) ។

២៧. មានឈ្មោះស្ទួនចំនួន ២៦៨,២១៨ ជាពិសេស នៅក្នុងតំបន់ដែលមានបញ្ហាច្រើន ដូចជារាជធានីភ្នំពេញ (អក្ខរាវិរុទ្ធនៃឈ្មោះ ថ្ងៃកំណើត និងយែនឌ័រគឺដូចគ្នា)។ ទន្ទឹមនឹងនេះមានពាក់កណ្តាល (១១៧,៩៦៩ គូរ) ឈ្មោះស្ទួនក្នុងខេត្តដូចគ្នា ហើយជិត២០% (២២,២៩៤ឈ្មោះគូរ) នៅក្នុងសង្កាត់ដូចគ្នា។ មានឈ្មោះស្ទួនចំនួន២៦៨,២១៨ គូរ នៅក្នុងតំបន់ដែលមានការប្រកួតប្រជែងខ្លាំង ដូចជារាជធានីភ្នំពេញ (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ ដូចគ្នាទាំងស្រុង) ។ លើសពីនេះ មានពាក់កណ្តាលឈ្មោះស្ទួន (១១៧,៩៦៩ឈ្មោះគូ) ត្រូវបានរកឃើញនៅក្នុងខេត្តតែមួយ និងជិត ២០% (២២,២៩៤ឈ្មោះគូ) ស្ថិតនៅក្នុងឃុំតែមួយ ។ បន្ទាប់ពីការបោះឆ្នោត គ.ជ.ប បានបដិសេធការប្តឹងតវ៉ាភ្លាមៗអំពីឈ្មោះស្ទួន និងបានរាយការណ៍ថាមានចំនួន ២៧០,០០០ ប៉ុណ្ណោះដែលមានឈ្មោះស្ទួនពិតប្រាកដ ។

២៨. អត្រានៃការចុះឈ្មោះពិតប្រាកដ - ភាគរយនៃប្រជាពលរដ្ឋកម្ពុជាដែលមានសិទ្ធិបោះឆ្នោត ដែលបច្ចុប្បន្ន ត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត - គឺ ៨៥,៤%[6] យោងតាមការត្រួតពិនិត្យកម្រិតខ្ពស់ ទៅលើសវនកម្មរបស់ NDI-NICFEC ។ ការវាស់វែងដូចគ្នា ជាមួយនឹងទិន្នន័យសវនកម្មរបស់ គ.ជ.ប បានបង្ហាញថាអត្រានៃ

ការចុះឈ្មោះ ៨២,៥% (នៃពលរដ្ឋមានសិទ្ធិបោះឆ្នោត ២,៥៧២ ដែលត្រូវបានសម្ភាសន៍ មាន ២,០៣៨ ត្រូវបានគេរកឃើញនៅក្នុងបញ្ជីបោះឆ្នោត) ។ អត្រានេះបានកើនឡើងរហូតដល់ ៨៧,៧% (២,១៦៩ នៃ ២,៥៧២នៃពលរដ្ឋមានសិទ្ធិបោះឆ្នោតដែលត្រូវបានរកឃើញ) បន្ទាប់ពី គ.ជ.ប បានធ្វើការស្វែងរក ទៅលើមូលដ្ឋានទិន្នន័យបញ្ជីបោះឆ្នោតពេញលេញរបស់ខ្លួន ។ ទោះជាយ៉ាងណា តួលេខផ្លូវការរបស់ គ.ជ.ប - ក្នុងបញ្ជីឈ្មោះបោះឆ្នោតមានអ្នកចុះឈ្មោះបោះឆ្នោត៩,៦៧៥,៤៥៣ ដែលមាន ១០១,៧% ។ ជាអកុសល មិនមានតួលេខស្ថិតិត្រឹមត្រូវនៃចំនួនប្រជាជននៅក្នុងប្រទេសកម្ពុជា ដែលមានតួលេខខុសគ្នាៗយ៉ាងសម្បើម ជាមួយនឹងទិន្នន័យផ្សេងៗនិងស្ថិតិប្រជាជន ដែលត្រូវបានប្រើប្រាស់ដោយក្រសួងតែមួយ ។

២៩. លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត (ICEs) គឺជាឯកសារបញ្ជាក់អត្តសញ្ញាណបណ្តោះអាសន្ន។ ក្រុមប្រឹក្សាឃុំសង្កាត់(មន្ត្រីជាប់ឆ្នោត) ចេញលិខិតនេះជូនប្រជាពលរដ្ឋគ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត។ គ.ជ.ប មិនទាន់បានចេញផ្សាយចំនួនច្បាស់លាស់នៃលិខិតICEs ដែលបានចែកចាយសម្រាប់ការបោះឆ្នោតនៅឡើយទេ បើទោះបីជាមានសំណើម្តងហើយម្តងទៀត ដែលបានស្នើសុំចំនួនសរុប ឬចំនួននៅតាមឃុំសង្កាត់។ ការប៉ាន់ប្រមាណទៅលើចំនួននៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៣ មានចំនួនប្រហែល ១,៨ លាននាក់ : មានការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតចំនួន ១,០៩៨,៨៩៣ សម្រាប់ការបោះឆ្នោត ឆ្នាំ ២០១២ និងប្រមាណជា ៧៥០,០០០ មុនការបោះឆ្នោតឆ្នាំ ២០១៣ ។ គ.ជ.ប បានបញ្ជាក់ថា ២៧០,០០០ICEs ឆ្នាំ ២០១៣ បានចេញជូនប្រជាពលរដ្ឋ នៅរវាងចុងបញ្ចប់នៃរយៈពេលនៃការចុះឈ្មោះបោះឆ្នោត និងពេលបោះឆ្នោត ។ បញ្ជីបោះឆ្នោតមានចំនួនប៉ោងធំ ដោយសារឈ្មោះខ្មោច ឈ្មោះស្ទួន អត្រានៃការចុះឈ្មោះដ៏លើសលុប និងកង្វះតម្លាភាពក្នុងដំណើរការនៃការចេញចំនួនលិខិតICEs ឬច្រើនលើសលប់ គួរតែតម្រូវឱ្យមានការស៊ើបអង្កេតមួយទៅលើបញ្ហានេះ។

៣០. ការព្រួយបារម្ភផ្សេងទៀត ផ្តោតលើចំនួនឈ្មោះច្រើនសន្ធឹកសន្ធាប់ និងចំនួនសរុបនៃបញ្ជីឈ្មោះប៉ោង និងការ បោះពុម្ពសន្លឹកឆ្នោតដ៏ច្រើនលើសលុប ។ គ.ជ.ប បានបោះពុម្ពសន្លឹកឆ្នោតចំនួន ១២,៣០៧,១៥០ សន្លឹក និងក្នុងនោះមានចំនួនសន្លឹកឆ្នោតបម្រុងចំនួន ២,៦លានសន្លឹក លើសពីចំនួនឈ្មោះនៅក្នុងបញ្ជី។ គ.ជ.ប បានបដិសេធមិនបង្ហាញចំនួនសន្លឹកឆ្នោតមិនបានការតាមការិយាល័យបោះឆ្នោត ដែលធ្វើឱ្យមានការលំបាកក្នុងការកំណត់ថាតើចំនួនសន្លឹកឆ្នោតត្រូវបានផ្ទៀងផ្ទាត់ដោយរបៀបណា ។

៣១. មានភាពមិនប្រក្រតីអំពីការអនុញ្ញាតឲ្យបោះឆ្នោតដោយគ្មានឯកសារបញ្ជាក់អត្តសញ្ញាណ និងឈ្មោះត្រឹមត្រូវ ឧទាហរណ៍មានករណីចំនួនប្រាំនៅរាជធានីភ្នំពេញ (ការិយាល័យបោះឆ្នោតលេខ ១១២, ២៩៦ និង ៩៨៧), ព្រៃវែង (ការិយាល័យបោះឆ្នោតលេខ៦៨៣) និងបាត់ដំបង (ការិយាល័យបោះឆ្នោតលេខ៣២០), ដែលអ្នកបោះឆ្នោតបានមកដល់ការិយាល័យបោះឆ្នោតជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណត្រឹមត្រូវ តែបែរជាឈ្មោះរបស់ខ្លួនត្រូវបានអ្នកផ្សេងប្រើដើម្បីបោះឆ្នោតរួចទៅវិញ ។ លើសពីនេះទៅទៀត នៅខេត្តកំពង់ចាម (ការិយាល័យបោះឆ្នោតលេខ ២២៨៣) បានរាយការណ៍ថា ឈ្មោះអ្នកបោះឆ្នោតម្នាក់ មានចំនួនពីរក្នុងបញ្ជី នៅក្នុងការិយាល័យបោះឆ្នោតតែមួយ ហើយមនុស្សម្នាក់ផ្សេងទៀតត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើឈ្មោះដែលលើសនោះ នៅខេត្តពោធិសាត់ (ការិយាល័យបោះឆ្នោតលេខ ៦៨៣) មនុស្សម្នាក់ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោត ដោយប្រើឈ្មោះផ្សេងដែលមិនមែនជារបស់ខ្លួន ។ (យោងតាម SBOរបស់TIC)

៣២. ស្ទើរតែគ្រប់ការិយាល័យបោះឆ្នោត៩៣%-មានការប្រើលិខិតICEs ប្រើដើម្បីបោះឆ្នោត ។ ១១% នៃការិយាល័យបោះឆ្នោត, អ្នកបោះឆ្នោតចំនួន ៥១នាក់ ឬច្រើនជាង បានប្រើ ICEs ដើម្បីបោះឆ្នោត (TIC SBO)។ សម្លេងឆ្នោតដែលគណបក្សកាន់អំណាចទទួលបានច្រើន ក្នុងខណៈពេលដែលមានការប្រើប្រាស់លិខិត ICEs ច្រើននៅក្នុងការិយាល័យបោះឆ្នោតបោះឆ្នោតនោះ (ការិយាល័យបោះឆ្នោតដែលTICសង្កេត)។

## គ. ការវិភាគអំពីការិយាល័យបោះឆ្នោត

៣៣. ភាពមិនធម្មតា កើតចេញពីការបង្កើតការិយាល័យបោះឆ្នោតនៅក្នុងតំបន់មួយចំនួន ។ ចំនួនការិយាល័យបោះឆ្នោត ច្រើនជាងពាក់កណ្តាល ត្រូវបានបន្ថែមក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២ បើទោះបីមានអាយុគ្រប់១៨ ឬអ្នកចំណាកស្រុកដ៏ច្រើនលើសលុបទៅកាន់តំបន់ទាំងនោះ ។ ខេត្តកំពង់ចាម កណ្តាល និងតាកែវ មាន១០០ការិយាល័យបោះឆ្នោតថែមទៀត នៅក្នុងពេលចុះឈ្មោះបោះឆ្នោតឆ្នាំ២០១២។ ដូចគ្នានេះដែរ ភាគរយដ៏ខ្ពស់នៃអ្នកបោះឆ្នោត ត្រូវបានគេយកចេញពី ការិយាល័យបោះឆ្នោតមួយចំនួន ក្នុងអំឡុងពេលចុះឈ្មោះឆ្នាំ២០១២ ។ ខេត្តសៀមរាប (១៣) និង ខេត្តបន្ទាយមានជ័យ (១១) មានចំនួនតួលេខនៃការិយាល័យខ្ពស់បំផុត ។ នេះបង្ហាញថា ជាងពាក់កណ្តាលនៃពលរដ្ឋដែលមានឈ្មោះក្នុងការិយាល័យបោះឆ្នោតនោះ បានស្លាប់ ឬ បានផ្លាស់ប្តូរទីលំនៅ ក្នុងអំឡុងពេលតែមួយឆ្នាំ។ ចំណែកការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតទាំងនោះ គណបក្សប្រជាជនទទួលបាន ៥៧,៩ % ហើយគណបក្សសង្គ្រោះជាតិទទួលបាន ៣៣% ខុសគ្នាពីភាគរយចំណែកនៃការបោះឆ្នោតទូទាំងប្រទេស (យោងតាម NDI)។

៣៤. យោងទៅតាមច្បាប់ដែលពាក់ព័ន្ធ ការិយាល័យបោះឆ្នោតមួយ មិនអាចមានអ្នកបោះឆ្នោតច្រើនជាង ៧០០ នាក់ បានទេ ដូច្នេះ គ.ជ.ប បង្កើតការិយាល័យបោះឆ្នោតថ្មីដើម្បីបំពេញចំនួនកើនឡើងនៃអ្នកបោះឆ្នោត ។ បន្ទាប់ពីមានការប្រៀបធៀបចំនួនការិយាល័យបោះឆ្នោត ឆ្នាំ ២០១២ និង ឆ្នាំ ២០១៣ NDI បានរកឃើញថាមាន ៩០២ ការិយាល័យបោះឆ្នោតថ្មី (៥%នៃចំនួនការិយាល័យសរុប១៩,០០៩) ដែលមិនមានក្នុងពេលបោះឆ្នោតឆ្នាំ២០១២។ ការិយាល័យបោះឆ្នោតទាំង៩០២បានបង្កើតនៅពេលដែលមានការ "បំបែក" ការិយាល័យបោះឆ្នោត ដែលមានស្រាប់ (៦៩១), ការផ្លាស់ប្តូរទីតាំងការិយាល័យ (២) និងការបង្កើតការិយាល័យថ្មីចំនួន (២០៩) ។ ការវិភាគបន្ថែមលើការិយាល័យថ្មីដែលបានបង្កើតចំនួន២០៩ ដែលមានលទ្ធផលបោះឆ្នោតលំអៀង និងអំណោយផលយ៉ាងខ្លាំងទៅរកគណបក្សប្រជាជនកម្ពុជាទទួលបានជាមធ្យម៧០%នៃអ្នកបោះឆ្នោត។ ទីពីរ ការិយាល័យបោះឆ្នោតថ្មីត្រូវបានរកឃើញថាមានអតុល្យភាពយេនឌ័រមានតិចជាង១០%នៃអ្នកដែលបានចុះឈ្មោះបោះឆ្នោតដោយឡែកនៅខេត្តព្រៃវែង និងកណ្តាល ។ ការិយាល័យបោះឆ្នោតថ្មី មានអត្រានៃអ្នកចុះឈ្មោះបោះឆ្នោតខ្ពស់មិនធម្មតា ។

## ឃ. ចំនួនអ្នកទៅបោះឆ្នោត

៣៥. យោងតាម គ.ជ.ប អ្នកចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ មាន ៦៩,៦១%នៃអ្នកបានចុះឈ្មោះបោះឆ្នោត ។ នេះគឺជាការធ្លាក់ចុះពី៧៥%នៅឆ្នាំ២០០៨ ។ គ.ជ.ប មិនបានផ្តល់ព័ត៌មានចំនួនសន្លឹកឆ្នោតមិនបានការ នៅតាមការិយាល័យបោះឆ្នោតឡើយ ។ ជាលទ្ធផល នៅក្នុងរបាយការណ៍នេះ បានបង្ហាញពីចំណែកនៃការបោះឆ្នោត (សន្លឹកឆ្នោតបានការសរុប) ប្រៀបធៀបទៅនឹងចំនួនអ្នកដែលបានចុះឈ្មោះនៅក្នុងការិយាល័យបោះឆ្នោតតែមួយ ។ មានការិយាល័យបោះឆ្នោតដែលមានចំនួនសរុបនៃសន្លឹកឆ្នោត លើស

ចំនួនប្រជាជនពេញវ័យ ផ្អែកតាមការប៉ាន់ប្រមាណចំនួនប្រជាពលរដ្ឋរបស់ទិន្នន័យមូលដ្ឋានឃុំសង្កាត់ (CDB)។ មានរហូតដល់ ១២០%នៃប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត។

## ង. ការស៊ើបអង្កេតក្រោយការបោះឆ្នោត

៣៦. ក្រោយពេលទទួលបានពាក្យបណ្តឹងជាផ្លូវការ គ.ជ.បតម្រូវឱ្យរៀបចំសវនាការជាសាធារណៈ ដែលមានវត្តមាននៃអ្នកចូលរួម ឬ តំណាង និងសាក្សីពាក់ព័ន្ធទាំងអស់ ។ ទោះជាយ៉ាងណា គ.ជ.ប មិនបានធ្វើសវនាការជាសាធារណៈណាមួយ និងបានធ្វើការសម្រេចនៅក្នុងកិច្ចប្រជុំបិទទ្វារផ្ទៃក្នុង ហើយបន្ទាប់មកបានប្រាប់ដើមបណ្តឹងអំពីការបដិសេធ ដោយគ្មានការពន្យល់ ឬការបង្ហាញពីលទ្ធផលនៃការស៊ើបអង្កេតណាមួយទេ ។ នៅទីបញ្ចប់ ពាក្យបណ្តឹងទាំងអស់ត្រូវបានច្រានចោលដោយគ្មានការពន្យល់ ។

៣៧. គណបក្សសង្គ្រោះជាតិបន្តដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ (CC) ដែលជាតុលាការកំពូលក្នុងការដោះស្រាយជម្លោះនៃការបោះឆ្នោត ។ ទោះបីជាមានច្បាប់ដែលមានស្រាប់ សម្រាប់អង្គភាព និងមុខងារនៃក្របខ័ណ្ឌ CC ប៉ុន្តែហាក់ដូចជាមិនមាននីតិវិធីច្បាស់លាស់ក្នុងការដោះស្រាយពាក្យបណ្តឹងនៃការបោះឆ្នោតនោះទេ ។ លើសពីនេះទៅទៀត សមាជិកក្រុមប្រឹក្សាភាគច្រើនរួមទាំងប្រធានក្រុមប្រឹក្សាដែលទទួលខុសត្រូវដោះស្រាយពាក្យបណ្តឹងនេះ បច្ចុប្បន្នគឺជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សប្រជាជន ។ ឆ្លើយតបទៅនឹងមាត្រាទី៤ ក្នុងបទប្បញ្ញត្តិផ្ទៃក្នុងបានបញ្ជាក់ថាៈ «សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវជាមន្ត្រីនៃគណបក្សនយោបាយណាមួយ» ។ ការស៊ើបអង្កេតទៅលើលទ្ធផលនៃការិយាល័យបោះឆ្នោត នៅមានកម្រិត ហើយហាក់ដូចជាមានមិនមានកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយ ឬ ទទួលស្គាល់ភាពមិនប្រក្រតីដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍ទាំងនេះ - ការឈ្មោះរបស់អ្នកចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតមិនត្រឹមត្រូវ និងខុសច្បាប់ ។

## V. សេចក្តីសន្និដ្ឋាន

៣៨. ជារួម ការបោះឆ្នោតនៅកម្ពុជាឆ្នាំ២០១៣ មិនមានភាពខុសគ្នានិងឆ្នាំមុនៗនោះទេ។ ការចាត់ចែងការបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ ការប្រើប្រាស់ធនធានរដ្ឋ និងការចែកអាសនៈ ត្រូវបានគេប្រមើលទុកជាមុនថា នឹងមិនត្រូវបានដោះស្រាយអោយត្រឹមត្រូវនោះទេសម្រាប់ការបោះឆ្នោតកាលពីថ្ងៃទី២៨ ខែកក្កដានេះ បើទោះបីជាបញ្ហាទាំងនេះជាបញ្ហាដដែលដែលធ្លាប់ត្រូវបានគេសិក្សា និងផ្តល់អនុសាសន៍ដោយទាំងអ្នកជំនាញជាតិ និងអន្តរជាតិក្តីក៏ដោយ។ របាយការណ៍នៅថ្ងៃបោះឆ្នោតបានកត់ត្រា(១) ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតត្រូវបានគេបដិសេធមិនអោយចូលក្នុងការិយាល័យបោះឆ្នោត (២)ការប្រើប្រាស់លិខិតបញ្ជាក់អត្តសញ្ញាណប័ណ្ណបំរើអោយការបោះឆ្នោតដែលចែកចាយដោយមន្ត្រីមូលដ្ឋានបក្ស (៣)អ្នកទៅបោះឆ្នោតមានចំនួនច្រើនជាងចំនួនប្រជាពលរដ្ឋដែលមាន (បើធៀបជាមួយទិន្នន័យមូលដ្ឋានឃុំសង្កាត់) (អាចបណ្តាលមកពីឈ្មោះស្ទួន និងឈ្មោះមិនបានការនៅក្នុងបញ្ជីបោះឆ្នោត) និង(៤)លទ្ធផលខុសធម្មតាពីការិយាល័យបោះឆ្នោតដែលបើកថ្មីៗជាមួយទិន្នន័យប្រជាជនមិនច្បាស់លាស់។

៣៩. នៅក្នុងបរិបទឆ្នាំ២០១៣ ជាពិសេសការផ្តោតទៅការបោះឆ្នោត បញ្ហាទាំងនេះគឺវាល្មមគ្រប់គ្រាន់ធ្វើអោយបាត់ទំនុកចិត្ត ឬជំនោះទៅលើដំណើរការបោះឆ្នោត។ ការបាត់ជំនឿនេះបានបង្ហាញអោយឃើញយ៉ាងច្បាស់ដោយការបន្តធ្វើពហិការរបស់គណបក្សសង្គ្រោះជាតិមិនចូលរួមក្នុងរដ្ឋសភា និងការតវ៉ាជាសាធារណៈ

ម្តងហើយម្តងទៀត ដែលនេះតំរូវឲ្យមានការទទួលខុសត្រូវគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដូចជាសង្គមស៊ីវិល សហគមន៍អន្តរជាតិ រដ្ឋាភិបាល និងគណបក្សនយោបាយ។

៤០. រដ្ឋាភិបាលបានធ្វើការឆ្លើយតបទៅសាធារណៈជនក្នុងការឲ្យមានការកែទម្រង់ការបោះឆ្នោតសម្រាប់ការបោះឆ្នោតលើកក្រោយ។ ដោយសារតែការងារនេះមានទំហំធំ រដ្ឋាភិបាលត្រូវតែធ្វើការងារនេះជាមួយអង្គការសង្គមស៊ីវិលដើម្បីធ្វើការផ្លាស់ប្តូរយោបល់ ការត្រួតពិនិត្យការបោះឆ្នោត និងគណបក្សនយោបាយដែលជាផ្នែកសំខាន់ដែលធ្វើអោយមានការកំណែទំរង់។

៤១. ជាដំបូងត្រូវតែពិនិត្យឡើងវិញទាំងស្រុងនូវរាល់ព័ត៌មានបោះឆ្នោត ដោយត្រូវការរួមសហការ និងចូលរួមរបស់គ.ជ.ប។ គ.ជ.ប គួរតែបង្ហាញទិន្នន័យ និងឯកសារដែលពាក់ព័ន្ធដលដល់សាធារណៈជន។ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) បានស្នើសុំជាច្រើនដងពីការចម្លងបញ្ជីបោះឆ្នោត ចំនួនលិខិតបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោតនៅតាមឃុំសង្កាត់នីមួយៗ ការសុំត្រួតពិនិត្យបញ្ជីបោះឆ្នោតដែលបានប្រើប្រាស់នៅការិយាល័យបោះឆ្នោត ។ ការទទួលបានឯកសារទាំងនេះគឺមានសារៈសំខាន់ណាស់សម្រាប់ធ្វើការវិភាគ។

៤២. គណបក្សនយោបាយទាំងអស់ធានាអោយបាននូវសុច្ចរិតភាពនៃការបោះឆ្នោតជំនួសមុខឲ្យសាធារណៈជនទូទៅ ដូច្នេះហើយគណបក្សនយោបាយអាចប្រើប្រាស់ការបោះឆ្នោតដើម្បីប្រកួតប្រជែងយកតំណែងរដ្ឋាភិបាលដោយត្រឹមត្រូវ។ គណបក្សទាំងអស់ត្រូវសហការគ្នាក្នុងការធ្វើឲ្យមានការកែទម្រង់ការបោះឆ្នោតដែលជាអាទិភាពទី១នៅក្នុងប្រទេសកម្ពុជា។

៤៣. សង្គមស៊ីវិលនឹងត្រូវដើរតួនាទីដឹកនាំឲ្យមានកំណែទម្រង់ការបោះឆ្នោត ដោយសារតែរដ្ឋាភិបាលបានបដិសេធបង្កើតឲ្យគណកម្មការឯករាជ្យស៊ើបអង្កេតការបោះឆ្នោតដែលមានការចូលរួមពីសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។ ការប្រឈមដែលអង្គការសង្គមស៊ីវិលកំពុងតែជួបប្រទះនាពេលបច្ចុប្បន្នគឺត្រូវធ្វើអោយការមិនពេញចិត្តរបស់សាធារណៈជនបន្ទាប់ពីការបោះឆ្នោតក្លាយជាចំនុចវិជ្ជមានដែលយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរយ៉ាងច្បាស់លាស់ទៅលើប្រព័ន្ធបោះឆ្នោត។

៤៤. សហគមន៍អន្តរជាតិត្រូវតែដោះស្រាយដើម្បីធ្វើអោយស្ថានភាពមានភាពប្រសើរបំផុត ជាជាងទុកអោយស្ថានភាពនេះនូវតែកើតមាន ហើយប្រឈមមុខជាមួយរឿងដដែលៗ ហើយទុកអោយវាកើតឡើងពេលបោះឆ្នោតនៅលើកក្រោយក្នុងប្រទេសកម្ពុជា។ សហគមន៍អន្តរជាតិត្រូវតែបន្តធ្វើអោយមានការកំណែទម្រង់គ្រប់រូបភាពទាំងអស់ដែលអាចធ្វើទៅបាន ដោយសហការជាមួយដៃគូ ខណៈពេលដែលសហគមន៍អន្តរជាតិត្រូវតែបន្តឧបត្ថមគាំទ្រដល់សង្គមស៊ីវិល ទាំងសំភារៈ និងបច្ចេកទេសនៅពេលដែលពួកគេធ្វើការងារទាក់ទងទៅនឹងការកែទម្រង់។

៤៥. ការលើកឡើងពីភាពមិនប្រក្រតីការបោះឆ្នោត និងអានុសាសន៍ពីការបោះឆ្នោតមុននៅក្នុងរបាយការណ៍នេះ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) ជឿជាក់ការកែទម្រង់សំខាន់ៗត្រូវតែរួមបញ្ចូលចំនុច៦ ក្នុងនោះរួមមាន៖ (១) សមាសភាព អាណត្តិ និងយុត្តាធិការនៃស្ថាប័នគ្រប់គ្រងការបោះឆ្នោតដែលបច្ចុប្បន្នគឺគ.ជ.ប (២) ដំណើរការចុះឈ្មោះបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ឯកសារដែលត្រូវការ និងការចែកចាយ និងភាពត្រឹមត្រូវនៃបញ្ជីឈ្មោះបោះឆ្នោត (៣) ការប្រើប្រាស់ ការចេញ និងការត្រួតពិនិត្យនៃលិខិតបញ្ជាក់អត្តសញ្ញាណ

បម្រើឲ្យការប្រើប្រាស់ (ICEs) (៤) គោលការណ៍ប្រើប្រាស់ដែលមានសមភាព តុល្យភាព និងការប្រើប្រាស់ដោយសេរី (៥) អព្យាក្រឹត្យភាពរបស់មន្ត្រីរាជការ តុលាការ និងកងកម្លាំងប្រដាប់អាវុធ (៦) ការកែទម្រង់ហិរញ្ញវត្ថុគណបក្សនយោបាយ។